ព្រឹត្តិបត្រព័ត៌មាន

# បេឡាជាតិរបបសន្តិសុខសង្គម
# National Social Security Fund

ប.ស.ស ឆ្នាំទី០៦ លេខ១១ ឆ្នាំ២០១៦




ធានាសន្តិសុខប្រាក់ចំណូល   រួមចំណែកកាត់បន្ថយភាពក្រីក្រ   លើកកម្ពស់ស្ថិរភាពសង្គម

## អ្នកមានជួយអ្នកក្រ
## អ្នកមានសុខភាពល្អជួយអ្នកឈឺ

សេវាសង្គ្រោះបន្ទាន់
**24h/7d**
**Hotline 1286**





# មាតិកា

ព្រឹត្តិបត្រព័ត៌មានបេឡាជាតិរបបសន្តិសុខសង្គម


១- រចនាសម្ព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម..........i

២- បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានសហការជាមួយអាជ្ញាធរ ខេត្តកំពង់ស្ពឺ រៀបចំប្រារព្ធពិធី ទិវាសប្តាហ៍ជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើកទី៩ ..........២

៣- វិនិយោគលើសមភាពយេនឌ័រ ដើម្បីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព..........៤

៤- ប.ស.ស បើកវគ្គបណ្តុះបណ្តាលជំនាញគ្រូបង្គោលទប់ស្កាត់ករណីសន្លប់ និងជួយសង្គ្រោះកម្មករសន្លប់..........៥

៥- សិក្ខាសាលា ស្តីពីដំណើរការនៃការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព សម្រាប់កម្មករនិយោជិត..........៧

៧- ក្រុមការងារ ស.ផ.ក បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំ ស្តីពីសុវត្ថិភាពលើមធ្យោបាយធ្វើដំណើររបស់កម្មករនិយោជិត..........៨

៨- បេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស បានរៀបចំពិធីផ្តល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត នៅក្រុងព្រះសីហនុ..........៩

៩- រថយន្តដឹកដូងប្រេងក្រឡាប់ បណ្តាលឱ្យកម្មករម្នាក់រងរបួសធ្ងន់ផ្នែកក្បាលខាងក្រោយ.១១

១០- កម្មករកម្មការិនីប្រមាណ ៣០នាក់ បម្រើការងារនៅរោងចក្រ អ៊ែរ៉ូស្វូហ្វ សាមីត ហ្វូតវែរ បានសន្លប់ បណ្តាលមកពីកម្មការិនីម្នាក់មានអាការៈក្អួតចង្អោរ ធឹងធោង វិលមុខ ទន់ដៃទន់ជើងបង្កឱ្យសន្លប់តៗគ្នា..........១២

១១- សេចក្តីជូនដំណើង ស្តីពីការចុះបញ្ជិកាកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម..........១៣

១២- អនុក្រឹត្យ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព..........១៥

១៣- អាហារដែលមានអត្ថប្រយោជន៍ដល់សុខភាព ..........២០

១៤- ក្រុមប្រចាំការ HOTLINE 24 ម៉ោង..........២១

១៥- ទស្សនអប់រំ ..........២២

១៦- អាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង សាខា ប.ស.ស តាមបណ្តារាជធានី-ខេត្ត...២៣

១៧- លេខទូរស័ព្ទទំនាក់ទំនងតាមមន្ទីរពេទ្យដែលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស..........២៧

១៨- លិខិតអនុញ្ញាតបន្តអាជ្ញាប័ណ្ណបោះពុម្ពផ្សាយព្រឹត្តិបត្រ ..........៣១






## រចនាសម្ព័ន្ធព្រឹត្តិបត្រ ប.ស.ស

លោក អ៊ុក សមវិទ្យា នាយក ប.ស.ស

ចាងហ្វាង លោក ជាវ ប៊ុនរិទ្ធ

និពន្ធនាយក លោក ឌួង ច័ន្ទតារា

និពន្ធនាយករង លោក ចាយ សំណាង

លេខានិពន្ធ លោកស្រី សុខ សូរ្យស្មី

កញ្ញា យ៉េម ចន្ធូ

ផ្នែកកុំព្យូទ័រ លោក យុន វិចិត្រ

លោក ពៅ សុវណ្ណារ៉ា

លោក ឱម សុផានិត

# រចនាសម្ព័ន្ធគ្រប់គ្រងបេឡាជាតិរបបសន្តិសុខសង្គម



# បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានសហការជាមួយអាជ្ញាធរ ខេត្តកំពង់ស្ពឺ រៀបចំប្រារព្ធពិធី ទិវាសប្តាហ៍ជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើកទី៩




សម្តេចក្រឡាហោម ស ខេង អញ្ជើញជាអធិបតីក្នុងពិធីទិវាសប្តាហ៍ជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើកទី៩ នៅខេត្តកំពង់ស្ពឺ

កាលពីរសៀលថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានសហការជាមួយអាជ្ញាធរខេត្តកំពង់ស្ពឺ រៀបចំប្រារព្ធពិធីទិវាសប្តាហ៍ជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើកទី៩ នៅកីឡាដ្ឋានខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក អមដោយ ឯកឧត្តមរដ្ឋមន្ត្រី ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងមានសមាសភាពចូលរួមពី លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស យុវជន កាកបាទក្រហម កាយរិទ្ធ បងប្អូនកម្មករនិយោជិត និងអ្នកបើកបរដឹកជញ្ជូនកម្មករនិយោជិតប្រមាណជាង ២000 នាក់។

លោក អ៊ុក សមវិទ្យា នាយកប.ស.ស បានមានប្រសាសន៍ថា៖ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល មានបេសកម្មបម្រើសេវាផ្នែកសាធារណៈមានលក្ខណៈសង្គម ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បច្ចុប្បន្ន ប.ស.ស បាននឹងកំពុងផ្តល់ធានារ៉ាប់រងហានិភ័យការងារ (គ្រោះថ្នាក់ការងារ) ដែលជាជំហានទី១ សំដៅលើគ្រោះថ្នាក់ ដែលកើតមានពេលកំពុងបំពេញការងារនៅក្នុងម៉ោងការងារ និងពេលធ្វើដំណើរពីផ្ទះត្រង់ឆ្ពោះទៅធ្វើការ ឬវិលមកគ្មានឈប់ ឬវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ។



លោក អ៊ុក សមវិទ្យា អញ្ជើញថ្លែងសុន្ទរកថាក្នុងអង្គពិធី



ទិដ្ឋភាពសិក្ខាកាមចូលរួមក្នុងអង្គពិធី

ឆ្លៀតក្នុងឱកាសនេះដែរ ក្នុងនាមអនុប្រធានក្រុមការងារផ្សព្វផ្សាយអប់រំដល់អ្នកបើកបររថយន្តដឹកកម្មករ អ្នកដំណើរ និងដឹកទំនិញ នៃក្រុមការងារទាំង៧ ចំណុះគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងជានាយក ប.ស.ស ជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុវត្តការងារយ៉ាងសស្រាក់សស្រាំ គិតចាប់ពីឆ្នាំ២០១៣ រហូតដល់ត្រឹមត្រីមាសទី១ ឆ្នាំ២០១៦

នេះ បានសម្រេចការងារជាលទ្ធផល ដូចខាងក្រោម៖

- ចុះផ្សព្វផ្សាយអប់រំ អំពីច្បាប់ចរាចរណ៍ផ្លូវគោក ជូនដល់កម្មករនិយោជិត និងអ្នកបើកបរដឹកកម្មករចំនួន ៧៣៥ រោងចក្រ មានអ្នកចូលរួមសរុបចំនួន ៤៩,៥៨៣ នាក់ កម្មករនិយោជិតចូលរួមចំនួន ៤១,៣៥៩ នាក់ និងអ្នកបើកបរដឹកកម្មករចំនួន ៨,២៣៣ នាក់។

- បានសហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន ចុះបណ្តុះបណ្តាលផ្នែកទ្រឹស្តី និងដៃចង្កូតត្រៀមប្រឡងយកបណ្ណបើកបរចំនួន ៥៤១ នាក់។ ប្រឡងយកបណ្ណបើកបរ និងជាប់ជាស្ថាពរចំនួន ៥១៩ នាក់។

- បានសហការជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន បានចុះរៀបចំបណ្តុះបណ្តាលគ្រូបង្គោលផ្នែកសុវត្ថិភាពចរាចរណ៍ ជូនបុគ្គលិករដ្ឋបាលរោងចក្រ ប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានចំនួន ៦២៤ នាក់។

ទន្ទឹមនឹកការអនុវត្តនេះ បេឡាជាតិរបបសន្តិសុខសង្គម ក៏បានយកចិត្តទុកដាក់ចំពោះសុខភាព របស់កម្មករនិយោជិតផង ដោយត្រៀមអនុវត្តជំហានទី២ តាមអនុក្រឹត្យលេខ ០១ អនក្រ/បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជូនកម្មករនិយោជិត ដែលនឹងចាប់អនុវត្តចាប់ពីខែឧសភា ឆ្នាំ២០១៦ នេះតទៅ។



សម្តេចក្រឡាហោម សរ ខេង ផ្តល់បណ្ណសរសើរ ជូនលោកនាយក ប.ស.ស



សម្តេចក្រឡាហោម សរ ខេង អញ្ជើញថ្លែងសុន្ទរកថាក្នុងអង្គពិធី

ជាមួយគ្នានេះ ប.ស.ស កំពុងរៀបចំដាក់ឱ្យអនុវត្តផ្នែកប្រាក់សោធននិវត្តន៍ ដែលជាជំហានទី០៣ របស់ខ្លួន នៅឆ្នាំ២០១៧ ខាងមុខ គម្រោងនេះមានគោលដៅលើកកម្ពស់សិទ្ធិមនុស្សសម្រាប់ជនចាស់ជរា ខាងវិស័យឯកជនដែលធ្វើការមិនកើតមានសិទ្ធិទទួលបានប្រាក់ចូលនិវត្តន៍ដូចមន្ត្រីរាជការដែរ៕



# វិនិយោគលើសមភាពយេនឌ័រដើម្បីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព

កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦ បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំពិធីទិវាសិទ្ធិនារីអន្តរជាតិ (International Women's Rights Day) ០៨ មីនា ខួបលើកទី១០៥ លើប្រធានបទ " វិនិយោគលើសមភាពយេនឌ័រដើម្បីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព"ក្រោមការដឹកនាំដោយលោក **អ៊ុក សមវិទ្យា** នាយកបេឡាជាតិរបបសន្តិសុខសង្គម និង សិក្ខាកាមដែលជាមន្ត្រីបុគ្គលិក ប.ស.ស ចូលរួមជាច្រើនរូប។ ពិធីនេះធ្វើឡើងរំលឹកដល់សន្និសីទទីក្រុង Copenhagen ប្រទេសដាណឺម៉ាក ដោយមានការចូលរួមពីនារីជាង ១00នាក់ មកពី ១៧ប្រទេស ក្នុងចំណោមនោះមាននារី០៣នាក់ ត្រូវបានជាប់ឆ្នោតតំណាងរាស្ត្រសភាហ្វាំងឡង់ផងដែរ។



ពិធីប្រគល់រង្វាន់លើកទឹកចិត្ត ដល់មន្ត្រី បុគ្គលិក ប.ស.ស ដែលជានារីក្នុងអង្គពិធី

គោលបំណងនៃប្រធានបទនេះ គឺធ្វើការបំផុស និងកៀងគរប្រជាពលរដ្ឋទាំងអស់នៅក្នុងប្រទេសកម្ពុជាឱ្យធ្វើការរួមគ្នា ដើម្បីឱ្យសម្រេចបាននូវសមភាពដ៏ពិតប្រាកដរវាងបុរស និង ស្ត្រី ក៏ដូចជាដើម្បីឱ្យ មានការទទួលស្គាល់ថាស្ត្រី គឺជាភ្នាក់ងារដ៏សំខាន់ដែលមានតួនាទីធ្វើឱ្យសង្គមផ្លាស់ប្តូរមុខមាត់ថ្មី។





នាយក ប.ស.ស រៀបចំពិធីអបអរ ០៨មីនា ទិវាសិទ្ធិនារីអន្តរជាតិ

ដើម្បីពន្លឿនការសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពមួយពោល គឺការធ្វើឱ្យមានសមភាពយេនឌ័រ ការលុបបំបាត់ការរើសអើង និងហឹង្សាទៅលើនារី និងកុមារ ព្រមទាំងធានាឱ្យបានការចូលរួមចំណែក និងមានឱកាសប្រជុំប្រសងគ្នារវាងបុរស និងនារីក្នុងការប្រឡូកក្នុងគ្រប់សកម្មភាពយេនឌ័រ និងនយោបាយផងដែរ។



សិក្ខាកាមដែលជាមន្ត្រីបុគ្គលិក ប.ស.ស ចូលរួមក្នុងពិធី

ចំពោះបេឡាជាតិរបបសន្តិសុខសង្គម ទោះជាអង្គភាពនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលក៏ដោយ ក៏ថ្នាក់ដឹកនាំនៅតែឆ្លៀតឱកាស ដើម្បីរៀបចំពិធីអបអរទិវាសិទ្ធិនារីផ្ទៃក្នុងជូននារី ប.ស.ស ជារៀងរាល់ឆ្នាំផងដែរ។ នេះបង្ហាញពីការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ ដល់នារីទាំងអស់។

# ប.ស.ស បើកវគ្គបណ្តុះបណ្តាលជំនាញគ្រូបង្គោលទប់ស្កាត់ករណីសន្ទប់ និងជួយសង្គ្រោះកម្មករសន្លប់

កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានរៀបចំពិធីបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលជំនាញទប់ស្កាត់ករណីសន្លប់ និងជួយសង្គ្រោះកម្មករសន្លប់ នៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន ដល់រដ្ឋបាលរោងចក្រ សហជីព និងប្រតិភូ-បុគ្គលិកចំនួន ៣៥ រោងចក្រ ស្មើនឹង ១០៥នាក់។



ឯកឧត្តម សេង សក្កា អញ្ជើញជាអធិបតីក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោល

គោលបំណង នៃវគ្គនេះធ្វើឡើងដើម្បីបណ្តុះបណ្តាលដល់រដ្ឋបាលរោងចក្រសហជីព និងប្រតិភូបុគ្គលិកទាំង១០៥ ឱ្យក្លាយជាជនបង្គោល ដើម្បីឲ្យមានមូលដ្ឋាន សម្រាប់យកទៅផ្សព្វផ្សាយអប់រំបន្តអំពីជំនាញទប់ស្កាត់ករណីសន្លប់ និងជួយសង្គ្រោះនៅពេលដែលកម្មករសន្លប់តាមសហគ្រាស គ្រឹះស្ថានរបស់ខ្លួន។

ចាប់តាំងពីឆ្នាំ២០០៨ រហូតមកដល់ ឆ្នាំ២០១៥ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានពង្រីកវិសាលភាពរបស់ខ្លួនលើរបបហានិភ័យការងារចំនួន ២៥ រាជធានី-ខេត្ត ទូទាំងប្រទេស បានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ចំនួន ៧,៧៩៦ សហគ្រាស។ ដោយឡែកសម្រាប់ឆ្នាំ២០១៥នេះ បេឡាជាតិរបបសន្តិសុខសង្គម បន្តចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន បានចំនួន ៧៥៥ សហគ្រាស គ្រឹះស្ថានបន្ថែមទៀត។



លោក អ៊ុក សមវិទ្យា អញ្ជើញថ្លែងសុន្ទរកថាក្នុងកិច្ចប្រជុំ

ដោយទទួលបានរបាយការណ៍ហានិភ័យការងារពីបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថាន តាមបណ្តារាជធានី-ខេត្ត នៅទូទាំងប្រទេស ចំនួន ២៧,៩១៦ ករណី មានកម្មករនិយោជិតចំនួន ៣០,២៨១ នាក់



សិក្ខាកាមដែលជាតំណាងរោងចក្រ សហគ្រាស គ្រឹះស្ថាន និងតំណាងសហជីបមូលដ្ឋានចូលរួមក្នុងកិច្ចប្រជុំ

នៅក្នុងលទ្ធផលអង្កេតគ្រោះថ្នាក់ការងារចំនួន ២២,២៨១ នាក់ គ្រោះថ្នាក់កន្លែងធ្វើការមានចំនួន ២២,៤៨៧ នាក់ គ្រោះថ្នាក់ពេលធ្វើដំណើរចំនួន ៧,៧៩១ នាក់ និងជំងឺវិជ្ជាជីវៈ ០៣ នាក់។ ករណីទាំងនេះបេឡាជាតិរបបសន្តិសុខសង្គមបានចេញសេចក្តីសម្រេចបើកផ្តល់តាវកាលិកហានិភ័យការងារជូនកម្មករនិយោជិត ដែលរងគ្រោះថ្នាក់ការងារសម្រាប់ការព្យាបាលនៅមន្ទីរពេទ្យ ការថែទាំ ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន អ្នកបាត់បង់សមត្ថភាពការងារ



បទបង្ហាញរបស់ ឯកឧត្តម ប៉ុក វណ្ណថាត ស្តីពីជំនាញទប់ស្កាត់ករណីសន្លប់




អចិន្ត្រៃយ៍ វិភាជន៍បូជាសព ឧត្តរជីវី តាវកាលិកអ្នកចាំថែរក្សា និងសេវាបុនរនីតិសម្បទា។ ហើយករណីនេះទាមទារឱ្យមានការចាត់វិធានការបង្ការ ទប់ស្កាត់ និងកាត់បន្ថយអត្រាគ្រោះថ្នាក់ឱ្យនៅកម្រិតទាបតាមផែនការដែលបានគ្រោងទុក។



ឯកឧត្តម សេង សក្កា អញ្ជើញថ្លែងសុន្ទរកថាក្នុងកិច្ចប្រជុំ

ជាក់ស្តែងនៅក្នុងឆ្នាំ២០១៥ ក្រុមការងារ ទ.ស.ប.ក បានចុះអង្កេត និងចាត់វិធានការកែលម្អភ្លាមៗ ពេលមានបាតុភាពកម្មករសន្លប់ចំនួន ៣២ រោងចក្រ មានកម្មករនិយោជិតសន្លប់ ១,៨០៦នាក់




លោក ជាវ ប៊ុនរិទ្ធ តំណាងនាយក ប.ស.ស ផ្តល់វិញ្ញាបនបត្រជូនសិក្ខាកាម

និងចុះប្រជុំផ្សព្វផ្សាយផ្ទាល់នៅទីកន្លែងការងារចំនួន ៩០ រោងចក្រ និងមានសមាសភាពចូលរួមប្រមាណជា ១៣,៤៥០ នាក់ រួមមាននិយោជក តំណាងនិយោជក/រដ្ឋបាល, តំណាងសហជីពមូលដ្ឋាន, ប្រតិភូបុគ្គលិក, ប្រធានក្រុម/ផ្នែក កម្មករនិយោជិត គ្រូពេទ្យគិលានដ្ឋាន និងសន្តិសុខរោងចក្រ។

# សិក្ខាសាលា ស្ដីពីដំណើរការនៃការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព សម្រាប់កម្មករនិយោជិត

កាលពីព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ **លោក អ៊ុក សមវិទ្យា** នាយកបេឡាជាតិរបបសន្តិសុខសង្គម និង **លោក Albert Tan** សមាជិកគណៈកម្មាធិការប្រតិបត្តិរបស់ GMAC បានអញ្ជើញជាអធិបតីក្នុងពិធីបើកអង្គសិក្ខាសាលា ស្ដីពីដំណើរការនៃការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព សម្រាប់កម្មករនិយោជិត




លោក អ៊ុក សមវិទ្យា ថ្លែងសុន្ទរកថាស្ដីពីការដាក់ឱ្យដំណើរការផ្នែកថែទាំសុខភាព

ប្រារព្ធធ្វើឡើងនៅសណ្ឋាគារភ្នំពេញ ដោយមានការអញ្ជើញចូលរួមពីនិយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន ប្រមាណជាង ២០០នាក់។

លោកនាយកបានលើកឡើងអំពីការដាក់ឱ្យដំណើរការរបបថែទាំសុខភាព កន្លងមកដោយយើងបានអនុវត្តសាកល្បងទទួលបានជោគជ័យ នៅតាមបណ្ដារោងចក្រមួយចំនួន។ លោកនាយកបន្ថែមទៀត ប.ស.ស នឹងត្រៀមដាក់ឱ្យដំណើរការផ្នែកថែទាំសុខភាព ដែលជាជំហានទី២ នាចុងឆ្នាំ២០១៦ នេះ។

ដើម្បីភាពងាយស្រួលក្នុងការបម្រើសេវាសាធារណៈជូនដល់បងប្អូនកម្មករនិយោជិត ដែលជាសមាជិក ប.ស.ស ឱ្យបានត្រឹមត្រូវ




លោក អ៊ុក សមវិទ្យា និង លោក Albert Tan អញ្ជើញជាអធិបតីបើកអង្គសិក្ខាសាលា

ទាន់ពេលវេលា ប.ស.ស បានកំណត់អត្តសញ្ញាណកម្មករនិយោជិតទៅតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា។ លោកក៏បានបន្ថែមថា បន្ទាប់ពីដំណើរការរបបថែទាំសុខភាពនេះ ប.ស.ស ក៏នឹងគ្រោងដាក់ឱ្យដំណើរការនូវរបបថ្មីមួយទៀត ដែលជាជំហានទី៣ គឺរបបប្រាក់សោធន សម្រាប់កម្មករនិយោជិត ដើម្បីឱ្យកម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់សោធន (ប្រាក់ចូលនិវត្តន៍) ដូចមន្ត្រីរាជការដែរ៕



សិក្ខាកាមតំណាងរដ្ឋបាលរោងចក្រ សហគ្រាសគ្រឹះស្ថាន សហជីពមូលដ្ឋាន និង អង្គភាពពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ



# ក្រុមការងារ ស.ផ.ក បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំ ស្តីពី សុវត្ថិភាពលើមធ្យោបាយធ្វើដំណើររបស់កម្មករនិយោជិត

ដោយគ្រោះថ្នាក់ចរាចរណ៍លើមធ្យោបាយដឹកជញ្ជូន និងមធ្យោបាយធ្វើដំណើររបស់កម្មករនិយោជិត ពីមួយថ្ងៃទៅមួយថ្ងៃនៅតែបន្តកើតឡើងជាបន្តបន្ទាប់។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៥ កន្លងមកនេះករណីគ្រោះថ្នាក់ចរាចរណ៍ នៅតែកើតឡើងជាបន្តបន្ទាប់ជាពិសេសលើមធ្យោបាយធ្វើដំណើររបស់កម្មករនិយោជិត។

ហេតុនេះហើយទើប **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការកែសម្រួលបន្ថែមសមាសភាពក្រុមការងារ ស.ផ.ក ចំនួនពីររូបបន្ថែមទៀត មកពីកាកបាទក្រហមកម្ពុជា និងសហភាពសហព័ន្ធយុវជនកម្មករ ដើម្បីការជំរុញចុះផ្សព្វផ្សាយអប់រំច្បាប់ ស្តីពីចរាចរណ៍ផ្លូវ-គោក វិជ្ជាសង្គ្រោះបឋម ដល់កម្មករនិយោជិត និយោជក ពិសេសអ្នកបើកបរដឹកកម្មករនិយោជិត។



បទបង្ហាញដោយគ្រូឧទ្ទេស ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោកថ្មី។

ដើម្បីចូលរួមក្នុងការកាត់បន្ថយនូវគ្រោះថ្នាក់ទាំងនេះ ទើបនៅក្នុងឆ្នាំ២០១៦ នេះក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំ អំពីច្បាប់ចរាចរណ៍ផ្លូវគោក និងសុវត្ថិភាពធ្វើដំណើររបស់កម្មករនិយោជិត។ តាមបណ្តាសហគ្រាសគ្រឹះស្ថាន ទូទាំងរាជធានី-ខេត្ត។

ទន្ទឹមគ្នានេះកាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ក្រុមការងារ ស.ផ.ក បានរៀបកិច្ចប្រជុំផ្សព្វផ្សាយអប់រំអំពីច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក និងសុវត្ថិភាពធ្វើដំណើររបស់កម្មករនិយោជិត និងបាន



អធិបតីចូលរួមក្នុងកិច្ចប្រជុំ

សហការណ៍ជាមួយក្រសួងសាធារណការ និងដឹកញ្ជូន រៀបចំប្រជុំផ្សព្វផ្សាយអប់រំនេះឡើង ដើម្បីណែនាំដល់កម្មករនិយោជិតឱ្យបានយល់ច្បាស់ពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បច្ចេកទេសត្រួតពិនិត្យយានយន្តប្រចាំថ្ងៃ និងវិជ្ជាសង្គ្រោះបឋម ដល់កម្មករនិយោជិត និងអ្នកបើកបរដឹកកម្មករនិយោជិត នៅរោងចក្រ Golden Apparel (Cambodia) ltd. ទាំងអស់ ដើម្បីរួមចំណែកទប់ស្កាត់ករណីគ្រោះថ្នាក់ចរាចរណ៍ឱ្យនៅកម្រិតទាបបំផុត និងរួមចំណែកយ៉ាងសកម្ម



ពិធីផ្តល់មួកសុវត្ថិភាពដល់សិក្ខាកាមចូលរួម

ក្នុងការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍លើមធ្យោបាយធ្វើដំណើររបស់កម្មករនិយោជិត៕

# បេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស បានរៀបចំពិធីផ្តល់ បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត

កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានរៀបចំពិធីផ្តល់បណ្ណបើកបរ និងវិញ្ញាបនបត្រគ្រូបង្គោលផ្នែកសុវត្ថិភាពចរាចរណ៍ ជូនដល់អ្នកបើកបរដឹកកម្មករដែលបានប្រឡងជាប់ជាស្ថាពរចំនួន ៦៦ នាក់ និងគ្រូបង្គោលចំនួន ៣៦ នាក់ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ ក្រោមអធិបតីភាព លោកឧត្តមសេនីយ៍ត្រី **លុយ ឈីន** អនុប្រធានក្រុមការងារ ស.ផ.ក តំណាង **លោក អ៊ុក សមវិទ្យា** ប្រធានក្រុមការងារ ស.ផ.ក។

បណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្ថែមសមាសភាពក្រុមការងា ស.ផ.ក ចំនួន ០២នាក់ទៀត មកពីកាកបាទក្រហមកម្ពុជា និងសហភាពសហព័ន្ធយុវជនកម្ពុជា។

ក្រុមការងារ ស.ផ.ក មានភារកិច្ចអប់រំច្បាប់ចរាចរណ៍ផ្លូវគោក បច្ចេកទេសសុវត្ថិភាពយាយន្ត វិជ្ជាសង្គ្រោះបឋម ជាពិសេសអ្នកបើកបរដឹកកម្មករនិយោជក នៅតាមរោងចក្រ សហគ្រាសគ្រឹះស្ថាន និងចុះអន្តរាគមន៍បន្ទាន់ នៅពេលដែលមានឧបទ្ទវហេតុកើតឡើង។

ក្រុមការងារ ស.ផ.ក បានសហការណ៍ជាមួយក្រសួងសាធារណការ




លោកឧត្តមសេនីយ៍ត្រី លុយ ឈីន អញ្ជើញជាអធិបតីក្នុងពិធីប្រគល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត

គ្រោះថ្នាក់ចរាចរណ៍លើមធ្យោបាយដឹកជញ្ជូន និងមធ្យោបាយធ្វើដំណើររបស់កម្មករនិយោជិតពីមួយថ្ងៃទៅមួយថ្ងៃកើតឡើងជាបន្តបន្ទាប់។ នៅក្នុងឆ្នាំ២០១៣ ក្រសួងបានចេញសេចក្តីសម្រេចបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក)។ ក្រុមការងារមានសមាសភាពមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសុខាភិបាល តំណាងនិយោជក (GMAC) តំណាងកម្មករនិយោជិត (សហជីព) និងអង្គការជនពិការអន្តរជាតិ។ នៅឆ្នាំ២០១៥ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និង



សិក្ខាកាមចូលរួមក្នុងអង្គពិធី



ការឡើងបញ្ចេញមតិរបស់សិក្ខាកាមក្នុងអង្គពិធី




លោក ជាវ ប៊ុនរិទ្ធ ធ្វើបទសម្ភាសជាមួយសារព័ត៌មាន

និងដឹកជញ្ជូន បណ្តុះបណ្តាលគ្រូបង្គោលផ្នែកសុវត្ថិភាពចរាចរណ៍ដល់រដ្ឋបាលរោងចក្រ សហជីពមូលដ្ឋាន និងបណ្តុះបណ្តាលប្រឡងយកបណ្ណបើកបរដល់អ្នកបើកបរដឹកកម្មករនិយោជិតដែលគ្មានបណ្ណបើកបរនៅតាមរោងចក្រ។

ជាក់ស្តែងគិតមកដល់បច្ចុប្បន្នក្រុមការងារសម្រេចបានចុះផ្សព្វផ្សាយអប់រំ អំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក (សុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូន និងសុវត្ថិភាពចរាចរណ៍លើការធ្វើដំណើររបស់កម្មករនិយោជិត) ជូនដល់កម្មករនិយោជិត និងអ្នកបើកបរដឹកកម្មករនិយោជិត បានចំនួន ៧៣៥ រោងចក្រ មានអ្នកចូលរួមសរុបចំនួន ៤៩.៥៩២ នាក់ ក្នុងនោះកម្មករនិយោជិតចូលរួមសរុបចំនួន ៤១.៣៥៩ នាក់ និងអ្នកបើកបរដឹកកម្មករនិយោជិតចំនួន ៨.២៣៣ នាក់ ក្នុងនោះគ្មានបណ្ណបើកបរចំនួន ៣.៥៩១ នាក់។

តាមរយៈការអនុវត្តការងារកន្លងមក ក្រុមការងារ ស.ផ.ក បានរកឃើញពីមូលហេតុជាសារវន្ត មួយចំនួនដែលបង្កឱ្យបងប្អូនកម្មករនិយោជិតមានគ្រោះថ្នាក់ចរាចរណ៍គឺ បណ្តាលមកពីបើកបរហួសល្បឿនកំណត់, បើកបរជែង ឬវ៉ា ក្នុងស្ថានភាពគ្រោះថ្នាក់, ក្នុងស្ថានភាពស្រវឹង,មិនគោរពសិទ្ធិគ្នា,មិនចេះអធ្យាស្រ័យគ្នាជាដើម៕



សកម្មភាពការផ្តល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត





# រថយន្តដឹកដូងប្រេងក្រឡាប់បណ្ដាលឱ្យកម្មករម្នាក់ រងរបួសធ្ងន់ផ្នែកក្បាលខាងក្រោយ

កាលពីព្រឹកថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង០៩ និង០៥ នាទី មានករណីគ្រោះថ្នាក់ការងារមួយធ្លាក់លើកម្មករបម្រើការងារនៅក្រុមហ៊ុនអឹមអរធីធីស៊ីស៊ីវិនិយោគទុនស្គរអំពៅ មានទីតាំងស្ថិតនៅភូមិអន្លង់ក្រពើ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ហេតុការណ៍គ្រោះថ្នាក់ខាងលើ កើតឡើងដោយរថយន្តដឹកផ្លែដូងប្រេងក្រឡាប់បណ្ដាលឱ្យកម្មករម្នាក់ ឈ្មោះ សេម វណ្ណ អាយុ ៣៤ឆ្នាំ រងរបួសផ្នែកក្បាលខាងក្រោយធ្ងន់។



សកម្មភាពគ្រូពេទ្យសង្គ្រោះជនរងគ្រោះ

ហេតុការណ៍គ្រោះថ្នាក់ខាងលើ មន្ត្រី ប.ស.ស សាខាខេត្តបានចុះ



ទៅជួយសម្របសម្រួលបញ្ជូនជនរងគ្រោះ ទៅសង្គ្រោះនៅមន្ទីរពេទ្យបង្អែកខេត្ត ដោយស្ថានភាពជនរងគ្រោះមានសភាពធ្ងន់ធ្ងរ ក៏បញ្ជូនបន្តទៅមន្ទីរពេទ្យកាលម៉ែត។ ចំពោះរាល់ការចំណាយលើសេវាដឹកជញ្ជូនជនរងគ្រោះ និងថ្លៃសេវាព្យាបាលរហូតជាសះស្បើយជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។



# កម្មការិនីប្រមាណ ៣០នាក់ បម្រើការងារនៅរោងចក្រ អ៊ែរ៉ូស្ទូហ្វ សាមីត ហ្វូតវែរ បានសន្លប់បណ្តាលមកពីកម្មការិនីម្នាក់មានអាការៈក្អួតចង្អោរ ធីងធោង វិលមុខ ទន់ដៃទន់ជើងបង្កឱ្យសន្លប់តៗគ្នា

ដោយករណីសន្លប់នៅតែបន្តកើតឡើង ចំពោះបងប្អូនកម្មករនិយោជិត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជំរុញឱ្យក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត (ទ.ស.ប.ក) បានចុះធ្វើការផ្សព្វផ្សាយអប់រំដល់កម្មករនិយោជិត ដើម្បីណែនាំដល់បងប្អូនកម្មករនិយោជិតឱ្យចេះការពារទប់ស្កាត់ករណីសន្លប់ឱ្យ នៅកម្រិតទាប។

ជាក់ស្តែង កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ មានករណីកម្មករកម្មការិនីបម្រើការងារនៅរោងចក្រ អ៊ែរ៉ូស្ទូហ្វ សាមីត ហ្វូតវែរ ដែលមានទីតាំងស្ថិតនៅ ឃុំតាស្តា ស្រុកសំពៅលូន ខេត្តបាត់ដំបង មានកម្មករកម្មការិនី មានអាការៈក្អួតចង្អោរ ធីងធោង វិលមុខ ទន់ដៃទន់ជើងបង្កឱ្យសន្លប់តៗគ្នាប្រមាណ ៣០ នាក់។

ករណីនេះដែរ មន្ត្រីសាខា ប.ស.ស ខេត្តចុះជួយសម្របសម្រួលជាមួយរដ្ឋបាលរោងចក្របានបញ្ជូនជនរងគ្រោះទៅសង្គ្រោះ នៅមន្ទីរពេទ្យបង្អែកសំពៅលូន។





រូបភាពជនរងគ្រោះកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ



ចំពោះរាល់ការចំណាយលើសេវាដឹកជញ្ជូនជនរងគ្រោះ និងថ្លៃសេវាព្យាបាលរហូតជាសះស្បើយ ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ទាំងស្រុង៕

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ : ១៤៨ ក.ប/ស.ជ.ណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចុះបញ្ជិកាកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបដល់ ម្ចាស់ នាយក សហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារថា ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨ សំដៅដល់ការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាពិសេសការរៀបចំ និងដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកសោធន ក្រសួងតម្រូវឲ្យចុះបញ្ជិកាកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមឡើងវិញ។

កន្លងមកក្រសួងសង្កេតឃើញថា មានបញ្ហាប្រឈមមួយចំនួន អំពីអត្តសញ្ញាណរបស់កម្មករនិយោជិត ដូចជា ការខ្ចីឈ្មោះអ្នកដទៃប្រើ, ការខុសឈ្មោះ, ការខុសភេទ, ការខុសថ្ងៃខែឆ្នាំកំណើត, ការខុសទីកន្លែងកំណើតជាដើម ដែលអាចបង្កឲ្យលេចចេញនូវបាតុភាពមិនប្រក្រតីនានា ធ្វើឲ្យភាគីពាក់ព័ន្ធជាពិសេស និយោជក និងកម្មករនិយោជិត មានការព្រួយបារម្ភចំពោះផលប៉ះពាល់តាមផ្លូវច្បាប់នានា ទាក់ទងនឹងការក្លែងឯកសារ, ការបាត់បង់អតីតភាពការងារ, ការបង់ថ្លៃសេវាពិនិត្យកាយសម្បទា, បណ្ណការងារ, សៀវភៅការងារ, បញ្ជិកាអង្គការវិជ្ជាជីវៈ ការបណ្តេញចេញពីការងារ ការចោទប្រកាន់ចំពោះការប្រើប្រាស់ពលកម្មកុមារ។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ និងចៀសវាងនូវរាល់បាតុភាពជាយថាហេតុ ម្ចាស់ នាយក សហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ កម្មករនិយោជិត និងអង្គភាពដែលពាក់ព័ន្ធត្រូវអនុវត្តដូចខាងក្រោម៖

១.មិនត្រូវចាត់ទុកជាកំហុស ចំពោះគ្រប់រូបភាពមិនប្រក្រតីខាងលើរបស់កម្មករនិយោជិត។

២.នៅពេលចុះបញ្ជិកាឡើងវិញ កម្មករនិយោជិតដែលមានបញ្ហាដូចខាងលើ ត្រូវបានរក្សានូវសិទ្ធិ និងអត្ថប្រយោជន៍ផ្សេងៗ ដូចជា អតីតភាពការងារ តួនាទីក្នុងអង្គការវិជ្ជាជីវៈ និងកិច្ចសន្យាការងារ។

៣.និយោជក មិនត្រូវទទួលបានការចោទប្រកាន់ថាប្រើប្រាស់ពលកម្មកុមារ ចំពោះករណីដែលកម្មករនិយោជិតប្រើអត្តសញ្ញាណខុសប្រក្រតីនេះទេ។

៤.កម្មករនិយោជិត ដែលទទួលបានការធ្វើនិយ័តកម្មអត្តសញ្ញាណឲ្យបានត្រឹមត្រូវឡើងវិញ មិនតម្រូវឲ្យមានការបង់ថ្លៃសេវាពិនិត្យកាយសម្បទា, បណ្ណការងារ សៀវភៅការងារ និងបញ្ជិកាអង្គការវិជ្ជាជីវៈ ចំពោះរាល់ការធ្វើនិយ័តកម្មឯកសារនេះឡើងវិញ។

៥.ក្នុងការជ្រើសរើសកម្មករនិយោជិតថ្មី សហគ្រាស គ្រឹះស្ថានចាំបាច់ត្រូវទាមទារឯកសារបញ្ជាក់អត្តសញ្ញាណរបស់សាមីខ្លួន ដូចជា អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សេចក្តីចម្លងសំបុត្រកំណើត ឬលិខិតឆ្លងដែន ឲ្យបានត្រឹមត្រូវ។

នៅក្នុងដំណើរការនៃការចុះបញ្ជិកាឡើងវិញ កម្មករនិយោជិត ត្រូវបំពេញសលាកបត្រព័ត៌មាន និងមានឯកសារផ្ទាល់ខ្លួនសំខាន់ៗ រួមមាន អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន សេចក្តីចម្លងសំបុត្រកំណើត សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ នាយកសហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ កម្មករនិយោជិត និងអង្គភាពពាក់ព័ន្ធនឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ វុសភា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព តាមច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅបង្កើតយន្តការផ្តល់ជូនសមាជិក ប.ស.ស នូវសេវាបង្ការសុខភាព និងតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ព្រមទាំងសហព័ទ្ធ និងកូនដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់នៃកម្មករនិយោជិតដែលជាសមាជិក ប.ស.ស និងសមាជិក ប.ស.ស ដែលកំពុងទទួលបានប្រាក់ធនលាភ ដោយការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ និងឧត្តរជីវី។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ថែទាំសុខភាព** សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គម ដែលត្រូវផ្តល់តាវកាលិក សេវាបង្ការសុខភាព តាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។
- **តាវកាលិក** សំដៅដល់ការផ្តល់សេវាបង្ការសុខភាព សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃនៅពេលសម្រាកព្យាបាលជំងឺឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងមាតុភាព។
- **សហព័ទ្ធ** សំដៅដល់ ប្រពន្ធ ឬប្តី ដែលនៅមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់។
- **ឧត្តរជីវី** សំដៅដល់អ្នកនៅរស់មានជីវិត ជាប្រពន្ធ ឬ ប្តី និងកូន នៅក្នុងបន្ទុកផ្ទាល់នៃសាមីជនដែលជាសមាជិកប.ស.ស ក្រោយពីទទួលមរណភាពដោយហានិភ័យការងារ។

## ជំពូកទី ២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៥.-**

បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ៦.-**

ក្រុមប្រឹក្សាជាន់ខ្ពស់មួយ ដែលជាបញ្ញត្តិករប្រព័ន្ធសន្តិសុខសង្គម ត្រូវបង្កើតឡើងដោយអនុក្រឹត្យដោយឡែក ដើម្បីគ្រប់គ្រងធ្វើអធិការកិច្ច តាមដាន ត្រួតពិនិត្យរាល់ការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពរបស់ ប.ស.ស និងកំណត់គោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម។

## ជំពូកទី ៣
## ភាគទាន តាវកាលិក និងប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព

### ផ្នែកទី ១
### ភាគទានផ្នែកថែទាំសុខភាព

**មាត្រា ៧.-**

និយោជក និងកម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាពជូនដល់ ប.ស.ស ។ ផ្នែកនៃភាគទានដែលជាបន្ទុករបស់កម្មករនិយោជិត មិនត្រូវលើសពីផ្នែកនៃភាគទានដែលជាបន្ទុករបស់និយោជកឡើយ។

អត្រាភាគទានផ្នែកថែទាំសុខភាព បែបបទ និងនីតិវិធីនៃការបង់ភាគទាននេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

### ផ្នែកទី ២
### តាវកាលិកផ្នែកថែទាំសុខភាព

**មាត្រា ៨.-**

តាវកាលិកផ្នែកថែទាំសុខភាព ដែលកំណត់ក្នុងអនុក្រឹត្យនេះរួមមាន ការផ្តល់សេវាបង្ការសុខភាព ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

ប្រភេទសេវា និងជំងឺដែលមិនទាន់ត្រូវបានដាក់បញ្ចូលក្នុងតាវកាលិកផ្នែកថែទាំសុខភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើពីក្រុមប្រឹក្សាភិបាល នៃ ប.ស.ស។

បែបបទ និងនីតិវិធី នៃការផ្តល់តាវកាលិកផ្នែកថែទាំសុខភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

យន្តការនៃការទូទាត់ចំណាយសេវាបង្ការសុខភាព ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

**មាត្រា ៩.-**

ការទទួលបានតាវកាលិកថែទាំសុខភាព ត្រូវអនុលោមតាមលក្ខខណ្ឌដែលពាក់ព័ន្ធនឹងរយៈពេលជាប់រង និងរយៈពេលយោង ដែលលក្ខខណ្ឌទាំងនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ផ្នែកទី ៣
## ប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព

**មាត្រា ១០.-**

ប្រាក់ត្រៀមបម្រុងអប្បបរមាផ្នែកថែទាំសុខភាព ត្រូវស្មើនឹងចំនួនទឹកប្រាក់ដែលបានចំណាយសម្រាប់តាវកាលិក ក្នុងអំឡុងពេល ០១ (មួយ) ឆ្នាំចុងក្រោយ ។

## ជំពូកទី ៤
## ការទទួលស្គាល់ និងការត្រួតពិនិត្យគុណភាព សេវារបស់មូលដ្ឋានសុខាភិបាល
## ផ្នែកទី ១
## ការទទួលស្គាល់គុណភាពសេវា

**មាត្រា ១១.-**

ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាល ដែលមានការទទួលស្គាល់ពីក្រសួងសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។

ការទទួលស្គាល់គុណភាពសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវអនុវត្តស្របតាមគោលការណ៍ដែលកំណត់ដោយក្រសួងសុខាភិបាល។

## ផ្នែកទី ២
## ការត្រួតពិនិត្យគុណភាពសេវា

**មាត្រា ១២.-**

គុណភាពសេវារបស់មូលដ្ឋានសុខាភិបាល ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដាន និងឃ្លាំមើលរបស់គណៈកម្មការវេជ្ជសាស្ត្រ នៃប.ស.ស។

សមាសភាព និងតួនាទីភារកិច្ចរបស់គណៈកម្មការវេជ្ជសាស្ត្រ នៃប.ស.ស ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ជំពូកទី ៥
## ដំណាក់កាលនៃការអនុវត្ត

**មាត្រា ១៣.-**

ដំណាក់កាលដំបូង ការផ្តល់សេវាថែទាំសុខភាពត្រូវអនុវត្តចំពោះតែសមាជិក ប.ស.ស និងឧត្តរជីវី។

ការផ្តល់សេវាថែទាំសុខភាពចំពោះសហព័ទ្ធ និងកូន ដែលនៅក្នុងបន្ទុកផ្ទាល់របស់សាមីជន ត្រូវអនុវត្តជាបន្តបន្ទាប់អនុលោមតាមស្ថានភាព សង្គម សេដ្ឋកិច្ចជាក់ស្តែង ដែលត្រូវកំណត់ដោយប្រកាសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
សូមហត្ថលេខា

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# អាហារដែលមានអត្ថប្រយោជន៍ដល់សុខភាព








# ទូរស័ព្ទ: ១២៨៦

# ក្រុមប្រចាំការ Hotline 24 ម៉ោង

ក្រុមការងារ Hotline ជាផ្នែកមួយដ៏សំខាន់ នៃបេឡាជាតិរបបសន្តិសុខសង្គម ដែលមានភ្នាក់ងារប្រចាំការ ២៤ម៉ោង ដើម្បីជួយសម្រួល និងផ្តល់ព័ត៌មាន ដល់បងប្អូនកម្មករនិយោជិត នៅពេលដែលជួបបញ្ហា ឬសាកសួរព័ត៌មានទាក់ទងទៅនឹងការបម្រើសេវាសាធារណៈ និងជួបគ្រោះថ្នាក់ដោយប្រការណាមួយហើយស្ថិតក្នុងម៉ោងការងារ។

ចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថាននានា រាល់ពេលមានបញ្ហាកើតឡើងបន្ទាន់មកលើកម្មករនិយោជិត សូមធ្វើការទំនាក់ទំនងមកកាន់ស្នាក់ការ ប.ស.ស ឬអាចធ្វើការរាយការណ៍មកកាន់ ប.ស.ស ថ្នាក់កណ្តាលតាមរយៈលេខទូរស័ព្ទ ១២៨៦ ហៅចេញបានគ្រប់ប្រព័ន្ធដោយឥតគិតថ្លៃ។

សម្រាប់ព័ត៌មានផ្សេងៗសូមធ្វើការទំនាក់ទំនង មកកាន់លេខទូរស័ព្ទ ០២៣ ៨៨២ ៨៣៤, ០២៣ ៩៩៨ ៩១៧, ០២៣ ៩៩៨ ៩១៨, ០២៣ ៩៩៨ ៩១៩ ឬអាចចូលទៅកាន់គេហទំព័ររបស់ ប.ស.ស មានដូចជា ៖ Email: Info@nssf.gov.kh និងគេហទំព័រ៖ Website nssf.gov.kh Page Facebook ដើម្បីទាញយកព័ត៌មានមួយចំនួនដែលទាក់ទង នឹងច្បាប់ការងារ ឬព័ត៌មានផ្សេងទៀតទាក់ទងនឹងរបបសន្តិសុខសង្គម។



សកម្មភាពទំនាក់ទំនងការងារ របស់អតិថិជនជាមួយក្រុមការងារ HotLine

# ទស្សនគ្គពិចារណា


កំហុសធំបំផុតរបស់មនុស្ស
គឺច្រឡំថាអ្វីដែលខ្លួនបាននិយាយ
សុទ្ធតែត្រឹមត្រូវ


បើអ្នកមិនបើកចិត្តឲ្យទូលាយ
ទទួលយកអ្វីដែលថ្មីនោះទេ
អ្នកនឹងគ្មានថ្ងៃរីកចម្រើន
ដាច់ខាត


អនាគតមិនទៀងទេ
អ្វីដែលទៀងគឺ
កើត ចាស់ ឈឺ ស្លាប់
PARK Café


អ្នកដទៃនិយាយអ្វី
មិនសំខាន់
សំខាន់ខ្លួនយើង
បានធ្វើអំពើល្អ


វិទ្យុ Cool FM 100.7
ភាពលំបាក
បង្រៀនមនុស្ស
ឲ្យចេះ
ខិតខំប្រឹងប្រែងតស៊ូ

# សាខា ប.ស.ស តាមបណ្តារាជធានី / ខេត្ត

| ខេត្តកណ្ដាល | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|
| អាសយដ្ឋានៈ ផ្ទះលេខ០១ ផ្លូវលេខ២០២, ភូមិដើមមៀន, សង្កាត់ដើមមៀន, ក្រុងតាខ្មៅ, ខេត្តកណ្ដាល | ០៨៥ ៥៦៧ ៧៦៦<br>០៧៧ ៩៦៣ ០៧៨ | ០២៤ ៦៤០ ១៦៧៦ | samphearak@nssf.gov.kh |
| **ខេត្តកណ្ដាល** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ភូមិក្នុង, ឃុំព្រែកតាមាក់, ស្រុកខ្សាច់កណ្ដាល, ខេត្តកណ្ដាល | ០៩៦ ៦១៥ ៦១៦៨<br>០១២ ៥៤៨ ៨០៥<br>០៩៨ ៥៤៨ ៨០៥ | ០២៣ ៥១៩ ៨៩៩៩ | nssf_reythearith@nssf.gov.kh |
| **ខេត្តកំពង់ស្ពឺ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្ទះលេខ៣៦A ភូមិស្វាយជ្រុំ, ឃុំបែកចាន, ស្រុកអង្គស្នួល, ខេត្តកណ្ដាល់ | ០១២ ២៨៦ ៨៧៩<br>០១៥ ២១០ ២១០<br>០៦០ ២១២ ២១២ | ០២៤ ៥០៨ ០៧៧៧ | movratha@yahoo.com |
| **ខេត្តព្រះសីហនុ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ សង្កាត់លេខ០៤, ក្រុងព្រះសីហនុ, ខេត្តព្រះសីហនុ | ០១៧ ៩៣៣ ៣៩៦<br>០៧៧ ៦៦៣ ២១៥ | ០៣៤ ៩៣៤ ៦០៦ | tong_samnieng@nssf.gov.kh |
| **ខេត្តស្វាយរៀង** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្លូវជាតិលេខ០១, ភូមិបាវិតលើ, សង្កាត់បាវិត, ក្រុងបាវិត, ខេត្តស្វាយរៀង | ០៧៧ ៦៦៣ ២១៤ | ០៤៤ ៧១៥ ៨៣១ | pek.samol@nssf.gov.kh |
| **ខេត្តកំពង់ឆ្នាំង** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្ទះលេខC៤៩៥, ក្រុមទី១៨, ភូមិម៉ុងបារាំង, សង្កាត់ប្អេរ, ក្រុងកំពង់ឆ្នាំង, ខេត្តកំពង់ឆ្នាំង | ០៧៧ ៦៦៣ ២១៦<br>០១៦ ៨៨៤ ៣៨៨ | ០២៦ ៩៨៨ ៨៩១<br>០២៦ ៧៧៥ ៥៦៦ | nssf_kcn@nssf.gov.kh |
| **ខេត្តសៀមរាប** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្ទះលេខP១០, ភូមិត្រពាំងសេះ, ឃុំគោកចក, ក្រុងសៀមរាប, ខេត្តសៀមរាប | ០១២ ៥៣៤ ៣៤៥<br>០៧៧ ៦៦៣ ២១៧ | ០៦៣ ៩៦៥ ៩៣៤ | pang_sokchea@yahoo.com<br>sokchea@nssf.gov.kh |

| ខេត្តបន្ទាយមានជ័យ | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|
| អាសយដ្ឋានៈ ភូមិគីឡូម៉ែត លេខ០៤, សង្កាត់ផ្សារកណ្តាល, ក្រុងប៉ោយប៉ែត, ខេត្តបន្ទាយមានជ័យ | ០៧៧ ៦៦៣ ២១៨<br>០៨៩ ៩៨៧ ៨៨៧ | ០៥៤ ៧១១ ៤៥១ | nssf_bmc@nssf.gov.kh |
| **ខេត្តកំពង់ចាម** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ភូមិទី១៤, សង្កាត់វាលវង់, ក្រុងកំពង់ចាម, ខេត្តកំពង់ចាម | ០១២ ៥២០ ៧៦៧<br>០៧៧ ៩៩០ ០៤៨ | ០៤២ ៦៥២ ១៩៩៩<br>០៤២ ៩៤៣ ៣៨៨ | say.sothon@nssf.gov.kh |
| **ខេត្តព្រៃវែង** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្ទះលេខ១០៧, ភូមិលេខ៣, សង្កាត់កំពង់លាវ, ក្រុងព្រៃវែង, ខេត្តព្រៃវែង | ០១២ ៥៤៨ ៨០៥<br>០៩២ ៧០៨ ៨០៣ | | reythearith@yahoo.com<br>rey.thearith@nssf.gov.kh |
| **ខេត្តតាកែវ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្លូវលេខ១០, ភូមិ០២, សង្កាត់រកាក្នុង, ក្រុងដូនកែវ, ខេត្តតាកែវ | ០១២ ៦៣៦ ៤៣៩ | ០៣២ ២១០ ៦៦៦ | vannak-rk@nssf.gov.kh<br>vannaknssf@gmail.com |
| **ខេត្តស្ទឹងត្រែង** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ភូមិថ្មលាត, សង្កាត់ស្រះឬស្សី, ក្រុងស្ទឹងត្រែង, ខេត្តស្ទឹងត្រែង | ០១២ ៤០៥ ៤៥១ | | nganrachana@gmail.com |
| **ខេត្តក្រចេះ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្លូវជាតិលេខ៧៣, ភូមិរកាកណ្តាលទី០១, សង្កាត់រកាកណ្តាល, ក្រុងក្រចេះ, ខេត្តក្រចេះ | ០៩២ ៨៧៣ ០៥១<br>០៩៧ ២៦២ ៧៥៤៧ | ០៧២ ២១០ ៤២៣ | kratie@nssf.gov.kh<br>soksay.he@nssf.gov.kh |

| ខេត្តកំពត | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|
| អាសយដ្ឋានៈ ភូមិ០១ឧសភា, ឃុំកំពង់កណ្តាល, ស្រុកកំពង់បាយ, ក្រុងកំពត, ខេត្តកំពត | ០១២ ៦២៣ ៣៣២<br>០៧២ ៦៨៨ ៨៨៦ | ០៣៣ ៩៣២ ១៣៣ | phokchetra@gmail.com sin.kosal@nssf.gov.kh |
| **ខេត្តពោធិ៍សាត់** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្ទះលេខ០០៧, ភូមិរ៉ា, សង្កាត់ផ្ទះព្រៃ, ក្រុងពោធិ៍សាត់, ខេត្តពោធិ៍សាត់ | ០៩២ ៧០៧ ៣៨៥ | ០៥២ ៩៥១ ១២៣ | nssf_ps@nssf.gov.kh |
| **ខេត្តបាត់ដំបង** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្ទះលេខB០៩, បូរីពាណិជ្ជកម្មបាត់ដំបង, សង្កាត់ស្វាយប៉ោ, ក្រុងបាត់ដំបង, ខេត្តបាត់ដំបង | ០៩៧ ៩៩៧ ២៨២៩ | ០៥៣ ៩៥៣ ៣៣៦ | battambang@nssf.gov.kh |
| **ខេត្តកោះកុង** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ផ្ទះលេខ២៦, ក្រុម២, ភូមិ៣, សង្កាត់ដងទង់, ក្រុងខេមរភូមិន្ទ, ខេត្តកោះកុង | ០៩៧ ៩៧៣ ៩០០៦<br>០១២ ៦២៥ ៨៥៥ | ០៣៥ ៩៣៦ ៤៣៦ | kongkea.nssf.kk@gmail.com |
| **ខេត្តប៉ៃលិន** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ភូមិវត្ត, សង្កាត់ប៉ៃលិន, ក្រុងប៉ៃលិន, ខេត្តប៉ៃលិន | ០៨៦ ៨៩៣ ៧៧៧ | ០៥៥ ៩៥៦ ៦៦៧ | somit.ream@nssf.gov.kh |
| **ខេត្តកំពង់ធំ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋានៈ ភូមិទី០៧, សង្កាត់កំពង់ធំ, ក្រុងស្ទឹងសែន, ខេត្តកំពង់ធំ | ០៩២ ៧៤៧ ០៩៩ | ០៦២ ២១០ ៤៦៣ | ly_sokha2007@yahoo.com |

| ខេត្តរតនគិរី | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|
| អាសយដ្ឋាន: ភូមិទេសអន្លង់,<br>សង្កាត់បឹងកន្សែង, ក្រុងបាលុង, ខេត្តរតនគិរី | ០១១ ៥៥១ ៧៧៧<br>០៩៧ ៩៦៦ ៧៦៦៦ | ០៧៥ ៩៧៤ ១៨៤ | sam_ath@nssf.gov.kh |
| **ខេត្តមណ្ឌលគិរី** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋាន: ភូមិចំបក់, សង្កាត់ស្ពានមានជ័យ,<br>ក្រុងសែនមនោរម្យ, ខេត្តមណ្ឌលគិរី | ០១២ ២០៥ ៧៥៦<br>០៨៨ ៨២០ ៥៧៥៦ | | kosol_vicheth@yahoo.com |
| **ខេត្តឧត្តរមានជ័យ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋាន: ភូមិឈូក, សង្កាត់សំរោង,<br>ក្រុងសំរោង, ខេត្តឧត្តរមានជ័យ | ០៩៧ ៥២៣ ៤៦៦៦<br>០៨៥ ៣១១ ៣០០ | | simmao2013@gmail.com |
| **ខេត្តព្រះវិហារ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋាន: ភូមិកណ្តាល,<br>សង្កាត់កំពង់ប្រណាក, ក្រុងព្រះវិហារ,<br>ខេត្តព្រះវិហារ | ០៩៧ ៣៦៦ ៦០៦ ០<br>០១២ ២៥៩ ២៥៨ | | nssf_pvh@nssf.gov.kh<br>savuthnou22@gmail.com |
| **សាខា ប.ស.ស ខណ្ឌដង្កោ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋាន: ផ្ទះលេខ១១២A, ផ្លូវវេងស្រេង,<br>សង្កាត់ចោមចៅ, ខណ្ឌពោធិ៍សែនជ័យ,<br>រាជធានីភ្នំពេញ, (ទល់មុខផែរស្វូតស្វូរង្គន) | ០១២ ៦៩៥ ៥៥០<br>០៨៦ ២៧១ ៣៧១ | ០២៣ ៩៩៥ ៤៨៤ | lpl@nssf.gov.kh |
| **សាខា ប.ស.ស ខណ្ឌឫស្សីកែវ** | **លេខទូរស័ព្ទដៃ** | **លេខទូរស័ព្ទលើតុ** | **E-mail** |
| អាសយដ្ឋាន: ផ្ទះលេខ៥០EoE1, ផ្លូវលេខ០៣,<br>ភូមិបឹងឈូក, សង្កាត់គីឡូម៉ែត០៦,<br>ខណ្ឌឫស្សីកែវ, រាជធានីភ្នំពេញ | ០៩២ ៤៨៦ ២៥៦<br>០៨៨ ៦៩១ ៦៩១១ | ០២៣ ៦៦៣ ៣០៣០ | vannaknssf@nssf.gov.kh |

# បញ្ជីឈ្មោះមូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស | រាជធានី/ខេត្ត |
|---|---|---|---|---|---|
| ០១ | មន្ទីរពេទ្យកាលម៉ែត | ១១៩ | ០២៣ ៤២៦ ៩៤៨<br>០២៣ ៧២៤ ៨៩១ | ០៩៧ ៦៨៧ ២៤២៦<br>០៩២ ១៥១ ៨៤៥ | ភ្នំពេញ |
| ០២ | មន្ទីរពេទ្យព្រះកុសុមៈ | ១១៩ | ០១២ ៦៥៧ ៦៥៣<br>០១៦ ៩០៩ ៧៧៤ | ០១៧ ៣៧៨ ៤៥៦<br>០៧៨ ៣២១ ៨១៨ | |
| ០៣ | មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ១១៩<br>០៧៨ ៩៩៧ ៩៧៨ | ០២៣ ២១៧ ៧៦៤<br>០១២ ៨៥៨ ១៨៤ | ០៧០ ៧៦៣ ៨៦៤<br>០១២ ៣៥៣៩១៦ | |
| ០៤ | មន្ទីរពេទ្យព្រះអង្គឌួង | ០១៦ ៥០៥ ៤៥៣ | ០១១ ៧៥៥ ១១៩<br>០៧៧ ៥៥០ ០១៧ | ០១០ ២៦៤ ០១៧<br>០១២ ៦៦៩ ៩៤៦ | |
| ០៥ | មណ្ឌលសុខភាពទួលគោក | ១១៩<br>០១២ ៥១៩ ៩១៦ | ០១១ ៨៣៣ ៣៣៩<br>០២៣ ៣៥១ ១៩៨ | ០១២ ៩១៨ ១៥៩<br>០១២ ៣៩៦ ០៨៥ | |
| ០៦ | មន្ទីរពេទ្យបង្អែកសម្តេចឪ | ១១៩<br>០៧៨ ៣៩៨ ៦៦៧ | ០១២ ៥៣២ ៨០៣<br>០១២ ៨៦៤ ៥០៩ | ០៧៨ ៦៦៨ ៨៩៧ | |
| ០៧ | មណ្ឌលសុខភាពទឹកថ្លា | ១១៩<br>០៧៧ ៧៩៧ ៩៦៧ | ០១៧ ៧២២ ០៦៥<br>០២៣ ៣៥១ ១៩៨ | ០១២ ៩១៨ ១៥៩<br>០១២ ៣៩៦ ០៨៥ | |
| ០៨ | មន្ទីពេទ្យបង្អែកពោធិ៍ចិនតុង | ១១៩<br>០១៧ ៧២២ ០៦៣ | ០១៧ ៧២២ ០៦៥<br>០២៣ ៣៥១ ១៩៨ | ០១២ ៨៨៤ ៧៦៦<br>០៧៨ ៦១៥ ៩៨៩ | |
| ០៩ | មណ្ឌលសុខភាពគោករកា | | ០១២ ៧៧៥ ៤៧២ | ០១២ ៩១៨ ១៥៩<br>០១២ ៣៩៦ ០៨៥ | |
| ១០ | មណ្ឌលសុខភាពស្ទឹងមានជ័យ | ០១២ ៩៧១ ៤៧៦<br>០១២ ៨៣៩ ១៦២ | ០១២ ៩៧១ ៤៧៦<br>០១១ ២៦២ ២៥៦ | ០៧៧ ៦៣៦ ៣៦០<br>០១២ ៩០៤ ៦៨០ | |
| ១១ | មណ្ឌលសុខភាពពញាពន់ | ០១២ ៧៩៦ ៩៩៦<br>០១០ ២៧៦ ៦៨៣ | | ០៩២ ៤៨៦ ២៥៦<br>០១២ ៨០៨ ៦៨៤ | |
| ១២ | មន្ទីរពហុព្យាបាល និងសម្ភព សុខ លាភ មេត្រី | ០១១ ៣៩៨ ៨៨៨ | ០២៣ ៦៦៦ ៦២៣៧<br>០១២ ៦០៣ ១៣១ | ០១២ ៩១៨ ១៥៩<br>០១២ ៣៩៦ ០៨៥ | |
| ១៣ | មន្ទីរសម្រាកព្យាបាលមូលមិត្ត | ០៩៧ ៧៦៣ ៩០០៣ | ០១២ ៤៤៩ ៦០៨ | ០៩២ ៣៤២ ២២៤<br>០៨៦ ៥៨២ ៤២៣ | |
| ១៤ | មន្ទីរពេទ្យជ័យជំនះ | ០១៥ ៥១៩ ១១៩ | ០១២ ៩១២ ៥២៣<br>០៧៧ ៩៣៣ ៤៥៩ | ០៩៧ ៦៨៧ ២៤២៨<br>០១២ ៣០៥ ៣៧១ | កណ្តាល |
| ១៥ | មណ្ឌលសុខភាពបែកចាន | ០១២ ១៧៥ ៨២៨៥<br>០៩៧ ៤៩៩ ៨៩៣៦ | ០១២ ៨៩៤ ២៦០ | ០៩៧ ២៩៩ ៦៦៦៩<br>០៩៦ ៣៦៩ ៥៩១២ | |
| ១៦ | មន្ទីរពេទ្យបង្អែកអង្គស្នួល | ០១២ ៥៨១ ៦៣៩ | ០១២ ៨៩៤ ២៦០<br>០៦៩ ៧០៥ ៧៥៧ | ០១២ ២៨៦ ៨៧៦<br>០៩២ ២២៧ ៧១២ | |
| ១៧ | មន្ទីពេទ្យបង្អែកកោះធំ | ១១៩<br>០១៧ ៧២២ ០៦៥ | ០២៣ ៣៥១ ១៩៨<br>០១៦ ៤៧១ ៨៨៧ | ០១២ ៥៤៨ ៨០៥ | |
| ១៨ | មន្ទីពេទ្យបង្អែកស្រុកស្អាង | ១១៩<br>០១៧ ៧២២ ០៦៥ | ០២៣ ៣៥១ ១៩៨ | ០៧៧ ៥៧០ ៩០៨ | |
| ១៩ | មណ្ឌលសុខភាពព្រែកអញ្ចាញ | ០១២ ៦៦៥ ០៣៩ | ០១៧ ៥៥២ ៣២៣<br>០១២ ៨៤០ ៥២០ | ០១២ ៥៤៨ ៨០៥ | |
| ២០ | មណ្ឌលសុខភាពវិហារសួគ៌ | ០៧៧ ៩២៦ ៦៩២ | ០១២ ៨៣២ ៣៤៣<br>០១២ ៤៩៥ ៩៨៣ | ០១២ ៥៤៨ ៨០៥ | |
| ២១ | មណ្ឌលសុខភាពសំរោងធំ | | ០៩៧ ៧៩៣ ៩៩៧៤<br>០១២ ៩៨៤ ៥៩០ | ០១២ ៩០៣ ៧៣៥<br>០១២ ៨៥៤ ២២៦ | |
| ២២ | មន្ទីរពេទ្យបង្អែកខ្សាច់កណ្តាល | ០៩៧ ៥៤០ ៤០០៦ | ០១២ ៤៤៦ ៥៩២<br>០១២ ៤៣៤ ៥៤៦ | ០១២ ៥៤៨ ៨០៥ | |

| | | | | | |
|---|---|---|---|---|---|
| ២៣ | មន្ទីរពេទ្យបង្អែកប៊ុន រ៉ានី ហ៊ុន សែន រកាកោង | ០១៧ ៥៥២ ៣២៣<br>០៩៧ ៩៥៣ ៩៥២៥ | ០៩២ ៤០៧ ៨៦៨ | ០១២ ៥៤៨ ៨០៤ | កណ្ដាល |
| ២៤ | មន្ទីរពេទ្យបង្អែកកំពង់ស្ពឺ | ០១៦ ៦៩៦ ៤៨០ | ០២៥ ៩៨៧ ៣១៣<br>០១៦ ៤៧១ ៨៨៧ | ០៩៧ ៧៨៣ ៩៣៩១ | កំពង់ស្ពឺ |
| ២៥ | មន្ទីរពេទ្យបង្អែកឧដុង្គ | ០៧៨ ៨៩១ ៩១៣<br>០១២ ៩១០ ០៦២ | ០១២ ៩៧៨ ៩២៥ | ០៩៧ ៧៨៣ ៩៣៩១<br>០១២ ២៨៦ ៨៧៩ | |
| ២៦ | មន្ទីរពេទ្យបង្អែកស្រុកគងពិសី | | ០៩៧ ៣៥៨ ៨៤៩០ | ០១២ ២៨៦ ៨៧៩<br>០៩២ ២២៧ ៧១២ | |
| ២៧ | មន្ទីរពេទ្យបង្អែកស្វាយរៀង | ០៤៤ ៩៤៥ ១១១ | ០១២ ៩៥៣ ៩៧៥ | ០៩៧ ៣៦៨ ៦៧៧៧<br>០៩៧ ២៨៥ ៦៦៤១ | ស្វាយរៀង |
| ២៨ | មន្ទីរពេទ្យបង្អែកជីភូ | ០១១ ៣៩៤ ១៧៨ | ០១២ ៨០៥ ២៣៦<br>០១២ ៧៦១ ០៨៩ | ០៩៧ ៣៦៨ ៦៧៧៧<br>០៩៧ ២៨៥ ៦៦៤១ | |
| ២៩ | មន្ទីរពេទ្យបង្អែកកំពង់ឆ្នាំង | ០២៦ ៩៨៨ ១១១ | ០១៥ ២៥០ ១១១<br>០១២ ៧០២ ២៥១ | ០៧៧ ៦៦៣ ២១៦<br>០១៦ ៨៨៤ ៣៤៨ | កំពង់ឆ្នាំង |
| ៣០ | មន្ទីរពេទ្យបង្អែកកំពង់ត្រឡាច | ០៨៥ ៥៨៧ ៧៥៧ | ០៨៥ ៥៨៧ ៧៩០<br>០១២ ៤៥៧ ៣០៨ | ០៨៨ ៩៧២ ១០១៦<br>០៧៧ ៦៦៣ ២១៦ | |
| ៣១ | មន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ | ០១៦ ៦៨៦ ៨៤៣ | ០១៦ ៧១២ ៦៤៦<br>០១២ ៧១២ ៦៤៦ | ០៧៧ ៦៦៣ ២១៥<br>០១៦ ៥៦៥ ៩៥៨ | ព្រះសីហនុ |
| ៣២ | មន្ទីរពេទ្យCT (ខេត្តព្រះសីហនុ) | ០៨៩ ៨៨៦ ៦៦៦<br>០៨៥ ៨៨៦ ៦៦៦ | ០៨១ ៨៨៦ ៦៦៦ | ០៧៧ ៦៦៣ ២១៥<br>០១៦ ៥៦៥ ៩៥៨ | |
| ៣៣ | មណ្ឌលសុខភាពវាលរេញ | ០១៦ ៤៥២ ៧៦១ | ០១៦ ២៦៩ ៧៤៤<br>០១២ ៩៨៣ ៦១២ | ០៧៧ ៦៦៣ ២១៥<br>០១៦ ៥៦៥ ៩៥៨ | |
| ៣៤ | មណ្ឌលសុខភាពអណ្ដូងថ្ម | | ០៩២ ៣៤០ ១៧១<br>០១៥ ៤៥៤ ៥៦២ | ០៧៧ ៦៦៣ ២១៥<br>០១៦ ៥៦៥ ៩៥៨ | |
| ៣៥ | មណ្ឌលសុខភាពរាម | | ០១៦ ៦៨៨ ៥៨៥<br>០៩៧ ៨៦៥ ៤៩០៣ | ០៧៧ ៦៦៣ ២១៥<br>០១៦ ៥៦៥ ៩៥៨ | |
| ៣៦ | មន្ទីរពេទ្យបង្អែកសៀមរាប | ០១៦ ៨០០ ១១៩ | ០១២ ៩២៥ ០៦១ | ០៧៧ ៦៦៣ ២១៧<br>០១២ ៣៨២ ៣២៣ | សៀមរាប |
| ៣៧ | មន្ទីរពេទ្យបង្អែកពួក | ០៨៨ ៨៣៤ ៦២៥៧ | ០៩២ ៩១០ ០២៧ | ០៧៧ ៦៦៣ ២១៧<br>០១២ ៥៣៤ ៣៤៥ | |
| ៣៨ | មន្ទីរពេទ្យបង្អែកប៉ោយប៉ែត | ០១២ ៧៨៦ ២៨៦ | ០១២ ៨៣៣ ១៥៩<br>០៨៩ ៨៣៧ ៦៣៧ | ០៩២ ៩០៩ ៤១៤<br>០៧៧ ៦៦៣ ២១៨ | បន្ទាយមានជ័យ |
| ៣៩ | មន្ទីរពេទ្យបង្អែកខេត្តមិត្តភាព កម្ពុជា-ជប៉ុន | ០១២ ៩៣២ ៥២១ | ០១២ ៩២៣ ៣៥៤<br>០៩៧ ៧៤០ ៥៤០១ | ០៩២ ៩០៩ ៤១៤<br>០៦៩ ២៥២ ៧៩៧ | |
| ៤០ | មន្ទីរពេទ្យបង្អែកសិរីសោភ័ណ | ០១២ ៩១០ ៤៦៧ | ០១២ ៨៥៤ ៩៨៣ | ០៩២ ៩០៩ ៤១៤<br>០៧៧ ៦៦៣ ២១៨ | |
| ៤១ | មន្ទីរពេទ្យបង្អែកស្រុកជើងព្រៃ | ០១២ ៦៦៧ ៤៨៨<br>០៨៨ ៧៧៤ ៤៧៨៨ | ០១៧ ៤២៣ ៥៤៨ | ០៩៣ ៨៧១ ០៤៣<br>០៧៧ ៩៩០ ០៤៨ | កំពង់ចាម |
| ៤២ | មន្ទីរពេទ្យបង្អែកស្រុកព្រៃឈរ | ០១១ ៣៩៨ ១៣៥<br>០៨៨ ៧៧៤ ៤៧៦៦ | ០៩៧ ៧៣៣ ២២៥៥<br>០៨៥ ៤១៤ ៥៥៦ | ០៧៧ ៩៩០ ០៤៨<br>០១២ ៨២២ ៤១១ | |
| ៤៣ | មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម | ០១២ ៨២៣ ៧០៩<br>០៩២ ៩៥៧ ៨៧១ | ០៩២ ៩៣៩ ៤៨០<br>០៩២ ៩១៧ ៣៨៨ | ០១២ ៥២០ ៧៦៧<br>០៧៧ ៩៩០ ០៤៨ | |
| ៤៤ | មន្ទីរពេទ្យបង្អែកព្រែកកក់ | ០១២ ៩០៤ ៣០៦<br>០៩២ ៣២២ ៤១៣ | ០១២ ៤៩៥ ១៤៨<br>០១១ ២៩៤ ៥៣២ | ០៧៧ ៩៩០ ០៤៨<br>០១២ ៨២២ ៤១១ | |
| ៤៥ | មន្ទីរពេទ្យបង្អែកស្រុកត្បូងឃ្មុំ | ០៨៨ ៧៧៤ ៤៧០០ | ០១១ ៨៦២ ០៣៩<br>០១២ ៤៩៥ ៦៥០ | ០៧៧ ៩៩០ ០៤៨<br>០១២ ៨២២ ៤១១ | ត្បូងឃ្មុំ |
| ៤៦ | មន្ទីរពេទ្យបង្អែកស្រុកមេមត់ | ០៨៨ ៧៧៤ ៤៧២២<br>០១២ ៩៦១ ៣៩៣ | ០១២ ៨៧៣ ១២៧ | ០៧៧ ៩៩០ ០៤៨<br>០១២ ៨២២ ៤១១ | |
| ៤៧ | មន្ទីរពេទ្យបង្អែកស្រុកពញាក្រែក | ០៨៨ ៧៧៤ ៤៧១១<br>០១១ ៦៦៩ ៤០៨ | ០៨៥ ៤១៤ ៨១៩<br>០៨៥ ៤១៤ ៨១៩ | ០៧៧ ៩៩០ ០៤៨<br>០១២ ៨២២ ៤១១ | |

| | | | | | |
|---|---|---|---|---|---|
| ៤៨ | មន្ទីរពេទ្យបង្អែកខេត្តក្រចេះ | ០៧២ ២១០ ៣៩១<br>០១២ ៨២២ ៣៩១ | ០១២ ៩៣១ ៨៦៨ | ០៩២ ៨៧៣ ០៥១<br>០៩៧ ៩៨៩ ៦៦៩១ | ក្រចេះ |
| ៤៩ | មន្ទីរពេទ្យបង្អែកស្រុកឆ្លូង | ០១២ ៥០២ ៩០៣<br>០១៧ ៩០៩ ៦៥៣ | ០១២ ៣៦៧ ៧០២ | ០៩២ ៨៧៣ ០៥១<br>០៩៧ ៩៨៩ ៦៦៩១ | |
| ៥០ | មន្ទីរពេទ្យបង្អែកស្រុកស្នួល | ០៩៧ ៧៥២ ៧៩៩៦ | ០៩៧ ៨០០ ៨៥៥៥<br>០៩៧ ៦៥៩ ៧២៩៩ | ០៨៨ ៦៧៧ ២៨៣២<br>០៩២ ៨៧៣ ០៥១ | |
| ៥១ | មន្ទីរពេទ្យបង្អែកអ្នកលឿង | ០១២ ៧៧៥ ៣១៩ | ០១២ ៦៦០ ៨១៥ | ០១២ ៥៤៨ ៨០៥<br>០៩៣ ២៨១ ០១៩ | ព្រៃវែង |
| ៥២ | មន្ទីរពេទ្យបង្អែកខេត្តព្រៃវែង | ០៩៧ ២៣៤ ១៧៨២<br>០១២ ៦៥៨ ៣០៣ | ០៩៧ ៧៩៥ ៧៤៧២<br>០១២ ៩២១ ២០០ | ០៩២ ៧០៨ ៨០៣<br>០៩៣ ២៨១ ០១៩ | |
| ៥៣ | មន្ទីរពេទ្យបង្អែកពារាំង | ០៩២ ៦៥៣ ៥៩៥<br>០១២ ៦៥៣ ៥៩៥ | ០៩២ ២២៣ ៦១៤<br>០៤៣ ៦៩០ ០៩០៥ | ០១២ ៥៤៨ ៨០៥<br>០៩២ ៧០៨ ៨០៣ | |
| ៥៤ | មន្ទីរពេទ្យបង្អែកស្វាយអន្ទរ | ០៩៧ ៥៥៧ ៧៦៤៧ | | ០១២ ៥៤៨ ៨០៥<br>០៩២ ៧០៨ ៨០៣ | |
| ៥៥ | មណ្ឌលសុខភាពក្ដៀងរាយ | ០១២ ៦៥៨ ៣០៣ | ០១២ ៤៣៩ ៣៤៣<br>០១២ ២៩៧ ៤៩១ | ០១២ ៥៤៨ ៨០៥<br>០៩២ ៧០៨ ៨០៣ | |
| ៥៦ | មន្ទីរពេទ្យបង្អែកស្រុកកំចាយមារ | ០១២ ៦៩៣ ៩៤០ | ០១២ ៥៨៨ ៤៩៥<br>០៩៥ ៨៨១ ៧០៧ | ០៩២ ៧០៨ ៨០៣<br>០៩៣ ២៨១ ០១៩ | |
| ៥៧ | មន្ទីរពេទ្យខេត្តតាកែវ | ០១២ ៩៣៥ ៨១៤ | ០១១ ៩០៥ ០១៩<br>០១២ ១៧២ ៨៣៤៨ | ០១២ ៩៣៩ ៤៣៩<br>០៧៧ ៥៧០ ៩០៥ | តាកែវ |
| ៥៨ | មន្ទីរពេទ្យបង្អែកបាទី | ០១២ ៧២៤ ០៩៣<br>០៩៧ ៦៤៧ ៤៣០៣ | ០៣២ ៦៩០ ១៩៣៩ | ០៧៨ ៧៨៩ ៩៥៥<br>០៩៧ ២០០ ២៨៥២ | |
| ៥៩ | មណ្ឌលសុខភាពត្រាំខ្នារ | ០៨១ ៤៤៤ ១៧៤<br>០១២ ៤២៤ ០៦៣ | ០៩៧ ៩៥៩ ៤៦៥៣<br>០១២ ៧២៤ ០៩៣ | ០១២ ៦៣៦ ៤៣៩<br>០៧៧ ៥៧០ ៩០៥ | |
| ៦០ | មន្ទីរពេទ្យភ្នែកតាកែវ | ០៩៧ ៨០១ ៦៧០៥<br>០១៦ ៣២០ ០៦៦ | ០១៦ ៩០៤ ៨៩០ | ០១២ ៦៣៦ ៤៣៩<br>០៧៧ ៥៧០ ៩០៥ | |
| ៦១ | មន្ទីរពេទ្យខេត្តកែប | ០១២ ៩១២ ៣២០ | ០១២ ៨២៥ ២៧៧<br>០១២ ៤៥៦ ២៤៧ | ០១២ ៩៩៣ ៨៧៧<br>០៨៨ ៨៥៥ ៩២៣៤ | កែប |
| ៦២ | មន្ទីរពេទ្យបង្អែកខេត្តស្ទឹងត្រែង | ០៩២ ៧៩៩ ៤៦៤<br>០៨៨ ៨៨៤ ៩៤៨៣ | ០៩៧ ៩៧៨ ០៨៧៨<br>០១២ ៩០៨ ៥៩០ | ០១២ ៤០៥ ៤៥១<br>០៩៨ ៩៦៨ ៤១៩ | ស្ទឹងត្រែង |
| ៦៣ | មន្ទីរពេទ្យបង្អែកខេត្តកំពត | ០១២ ២៩៧ ២៦៨ | ០១២ ៣១៦ ១៣៥<br>០១២ ៩៥៥ ៩៨៦ | ០១២ ៦២៣ ៣៣២<br>០៨៨ ៨៥៥ ៦២៣៤ | កំពត |
| ៦៤ | មន្ទីរពេទ្យបង្អែកកំពង់ត្រាច | ០១២ ៧៣៣ ៤៦៨ | ០៩២ ៣៨៣ ៦៣២<br>០៨៨ ៨៧៣ ២៤៦៨ | ០១២ ៦២៣ ៣៣២<br>០៨៨ ៨៥៥ ៦២៣៤ | |
| ៦៥ | មន្ទីរពេទ្យខេត្តពោធិ៍សាត់ | ១៣៥៣/០០១០ | ០១២ ៨២៨ ៤៦៦ | ០៩២ ៧០៧ ៣៨៥<br>០១៧ ៣៩២ ៥៥២ | ពោធិ៍សាត់ |
| ៦៦ | មណ្ឌលសុខភាពឈើតុំ | ០៩២ ៣០៧ ២៧៨ | | ០៩២ ៩៣៤ ០៩៤<br>០១៧ ៣៩២ ៥៥២ | |
| ៦៧ | មន្ទីរពេទ្យបង្អែកស្រុកក្រគរ | ០៩២ ៨១១ ១៦១ | ០៩៧ ១២២ ២៣៤៤ | ០៩២ ៧០៧ ៣៨៥<br>០១៧ ៣៩២ ៥៥២ | |
| ៦៨ | មន្ទីរពេទ្យបង្អែកស្រុកភ្នំក្រវាញ | ០១២ ៨៥០ ៥៩០ | | ០៩២ ៧០៧ ៣៨៥<br>០១៧ ៣៩២ ៥៥២ | |
| ៦៩ | មណ្ឌលសុខភាពស្នាមព្រះ | | ០៩២ ៦៧៧ ៦៨៥ | ០៩២ ៧០៧ ៣៨៥<br>០១៧ ៣៩២ ៥៥២ | |
| ៧០ | មន្ទីរពេទ្យបង្អែកបាកាន | ០៧៨ ៦៨១ ៤៧៤<br>០៩៧ ៦៦៨ ៧៥៤២ | | ០៩២ ៧០៧ ៣៨៥<br>០១៧ ៣៩២ ៥៥២ | |
| ៧១ | មន្ទីរពេទ្យបង្អែកស្រែអំបិល | ០១៦ ២២២ ១៨៦ | ០១៦ ៨៧៧ ០០៦ | ០១២ ៧៣៣ ៦២៧<br>០៩៧ ៩៧៣ ៩០០៦ | កោះកុង |
| ៧២ | មន្ទីរពេទ្យបង្អែកខេត្តកោះកុង | ០១៦ ៣០០ ១១៩ | ០១៦ ២០៤ ៨៨៧<br>០៩៧ ៧៩៥ ៨៧៨៨ | ០១២ ៦២៥ ៨៥៥<br>០៩៧ ៩៧៣ ៩០០៦ | |

| | | | | | |
|---|---|---|---|---|---|
| ៧៣ | មន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន | ០៩៧ ៦២៨ ៤៣៣៣ | ០៩៧ ៧៦៩ ៩៨៣៧<br>០៧១ ៩១៤ ៤៤១៨<br>០១៥ ៥៣២ ៣២៣ | ០៨៦ ៨៩៣ ៧៧៧<br>០១២ ៥០៥ ៤៨៨ | ប៉ៃលិន |
| ៧៤ | មន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង | ០១២ ២៦៩ ៣៨៨<br>០១២ ៨៣៣ ២៦១ | ០១២ ៨៣៣ ២៦១ | ០៩៥ ៨៨៥ ៨៥៥<br>០៩៧ ៩៩៧ ២៨២៩ | បាត់ដំបង |
| ៧៥ | មណ្ឌលសុខភាពត្រាង | ០៩៥ ២២៨ ៨៩៣<br>០៩៧ ៩១៤ ៥៨៧០ | ០១៧ ២៦៩ ៣៦៣ | ០៩៧ ៩៩៧ ២៨២៩ | |
| ៧៦ | មណ្ឌលសុខភាពស្តៅ | ០១២ ៥៨១ ៦៥៤<br>០៩២ ២៦៤ ១៦៣ | ០១២ ៦៧០ ៩៩៦ | ០៩៧ ៩៩៧ ២៨២៩ | |
| ៧៧ | មន្ទីរពេទ្យបង្អែកសំពៅលូន | ០១២ ៩៧៤ ២២៣<br>០៨៨ ៩១៨ ១០០៥ | ០១២ ៤៤៨ ១៩៦ | ០៩៧ ៩៩៧ ២៨២៩ | |
| ៧៨ | មន្ទីរពេទ្យបង្អែកថ្មគោល | ០៩២ ៧៨៦ ៣៥៦ | ០៩២ ៩០៣ ៤៩៤<br>០១២ ៧០១ ១៦០ | ០៩៧ ៩៩៧ ២៨២៩ | |
| ៧៩ | មន្ទីរពេទ្យបារាយណ៍-សន្ទុក | ០១២ ៩២៧ ១៤២<br>០១២ ៧៨២ ៤១៧ | ០១៧ ៥៥៩ ៣៨៧<br>០១២ ៨៦៧ ៥៧៣ | ០៩២ ៧៦៤ ៨៩៧<br>០៩៧ ៥០០ ០៤៥០ | កំពង់ធំ |
| ៨០ | មន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ | ០១៧ ៣៩៨ ៧៥០<br>០១២ ៩៤៧ ៩៣២ | ០៩២ ៩៥៤ ៣៦៧ | ០៩០ ៨៨៥ ៦៩៨<br>០៩២ ៣៤៧ ០៩៩ | |
| ៨១ | មន្ទីរពេទ្យបង្អែកស្ទោង | ០១២ ៧៦៨ ៤៤៣<br>០១២ ៧៩៤ ៣៤៩ | ០៩២ ២៩១ ៩៥៩ | ០៩០ ៨៨៥ ៦៩៨<br>០៩២ ៣៤៧ ០៩៩ | |
| ៨២ | មន្ទីរពេទ្យបង្អែកខេត្តរតនគិរី | ០១៧ ៩៣៦ ៩៤៥<br>០១២ ៨៤០ ៨០៨ | ០១២ ៥០៥ ០០៨<br>០១២ ៥២៨ ០០៨ | ០៩៧ ៩៦៦ ៧៦៦៦<br>០១១ ៤៥១ ៧៧៧ | រតនគិរី |
| ៨៣ | មន្ទីរពេទ្យបង្អែកបរកែវ | ០៩៧ ៩៩០ ៩៨៩៩ | ០១១ ៨៣៨ ៣០០<br>០១២ ៥១១ ៣៦៩ | ០៩៧ ៩៦៦ ៧៦៦៦<br>០១១ ៤៥១ ៧៧៧ | |
| ៨៤ | មន្ទីរពេទ្យបង្អែកសែនមនោរម្យ | ០៩៧ ៧១២ ១៤៤៥<br>០១២ ៩៦១ ៧៤៤ | ០៩៧ ៤៧៣ ៩៦៨៥<br>០៨៨ ៩៩៨ ៦៥៦៦ | ០១២ ២០៥ ៧៥៦<br>០៩៧ ៩០០ ០១០៩ | មណ្ឌលគិរី |
| ៨៥ | មណ្ឌលសុខភាពអូររអាម | ០៩៧ ៤៧៨ ៧៧៩៧ | ០១១ ៦០៧ ៧៨៣<br>០៨៨ ៣៣២ ៩១១៨ | ០១២ ២០៥ ៧៥៦<br>០៩៧ ៩០០ ០១០៩ | |
| ៨៦ | មណ្ឌលសុខភាពកែវសីម៉ា | ០៩៧ ៦៧៨ ៨៥៣៣ | ០១២ ២៦៦ ១៥២<br>០៩៧ ៨៥០ ៤៧៦៥ | ០១២ ២០៥ ៧៥៦<br>០៩៧ ៩០០ ០១០៩ | |
| ៨៧ | មន្ទីរពេទ្យបង្អែកខេត្ត ឧត្តរមានជ័យ | ០៩២ ១៤១ ៨៣៥<br>០១២ ៧២៣ ១២១ | ០៧៨ ២២៩ ៧៩៧<br>០៧៨ ៩៧៩ ៧២៩ | ០៩៧ ៥២៣ ៤៦៦៦<br>០៩៧ ៧៦២ ៨៨២៨ | ឧត្តរមានជ័យ |
| ៨៨ | មន្ទីរពេទ្យបង្អែកស្រុកអន្លង់វែង | ០៧៦ ៥២៦ ២៤៩១ | ០៧៧ ៥០៨ ០៥៧<br>០១១ ៦៧០ ១៧៤ | ០៩៧ ៥២៣ ៤៦៦៦<br>០៩៧ ៧៦២ ៨៨២៨ | |
| ៨៩ | មណ្ឌលសុខភាពអូរស្មាច់ | ០១១ ៧៣៦ ៨៨៦ | | ០៩៧ ៥២៣ ៤៦៦៦<br>០៩៧ ៧៦២ ៨៨២៨ | |
| ៩០ | មន្ទីរពេទ្យបង្អែក ១៦ មករា | ០១២ ៣៧១ ៦១៨ | ០១២ ៤២៦ ៥១៩<br>០១២ ៨៩២ ៩០៩ | ០៩៧ ៣៦៦ ៦០៦០<br>០៨៨ ៧៤៦ ២៧៧៤ | ព្រះវិហារ |
| ៩១ | មណ្ឌលសុខភាពភ្នំដែក | ០៩២ ២២៧ ៦១៦ | ០៩៧ ៣៩៤ ៤៦៦៩<br>០៩២ ៩៥៦ ៥៦៩ | ០៩៧ ៣៦៦ ៦០៦០<br>០៨៨ ៧៤៦ ២៧៧៤ | |
| ៩២ | មណ្ឌលសុខភាពជាំក្សាន្ត | | ០១២ ៩៣៨ ១៥៩<br>០៩៧ ៧៥២ ៧៧៧៣ | ០៩៧ ៣៦៦ ៦០៦០<br>០៨៨ ៧៤៦ ២៧៧៤ | |
| ៩៣ | មណ្ឌលសុខភាពស្រអែម | | ០៩៩ ៣៥៨ ៤៤៧ | ០៩៧ ៣៦៦ ៦០៦០<br>០៨៨ ៧៤៦ ២៧៧៤ | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
មន្ទីរព័ត៌មានរាជធានីភ្នំពេញ
លេខ...៣៥៤........ពមរ

ភ្នំពេញ,ថ្ងៃទី..២២..ខែ..ធ្នូ......ឆ្នាំ២០១៥

# លិខិតអនុញ្ញាត

## ប្រធានមន្ទីរព័ត៌មានរាជធានីភ្នំពេញ

**យោង:** -ប្រកាសលេខ១០៨ព.ម.ប្រ.ក ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ របស់ក្រសួងព័ត៌មាន។

-លិខិតអនុញ្ញាតលេខ០១៥ព.ម.រ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៥ របស់មន្ទីរព័ត៌មានរាជធានីភ្នំពេញ។

-ពាក្យស្នើសុំអនុញ្ញាតបន្តអាជ្ញាប័ណ្ណបោះពុម្ពផ្សាយព្រឹត្តិបត្រ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ របស់លោក **ជាវ ប៊ុនរិទ្ធ** ចាងហ្វាងការផ្សាយព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម**។

តាមសេចក្តីយោងខាងលើនេះ មន្ទីរព័ត៌មានរាជធានីភ្នំពេញ សូមជម្រាបជូនមកលោក ជាវ ប៊ុនរិទ្ធ ចាងហ្វាងការផ្សាយព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម** ជ្រាបថា មន្ទីរព័ត៌មានរាជធានីភ្នំពេញ អនុញ្ញាតឲ្យលោកចាងហ្វាងបន្តដំណើរការបោះពុម្ពផ្សាយចាងហ្វាងការផ្សាយព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម** ដែលមានទីស្នាក់ការនៅអាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ បន្តពីលិខិតអនុញ្ញាតលេខ០១៥ព.ម.រ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៥ របស់មន្ទីរព័ត៌មានរាជធានីភ្នំពេញ។

ក្នុងដំណើរការបោះពុម្ពផ្សាយ លោកចាងហ្វាងត្រូវគោរពអនុវត្តឲ្យបានត្រឹមត្រូវតាមខ្លឹមសារប្រកាសរបស់ក្រសួងព័ត៌មាន ដូចយោងខាងលើ។

ករណីប្រព្រឹត្តល្មើស នឹងប្រកាសអនុញ្ញាតរបស់ក្រសួងព័ត៌មាន សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

លិខិតអនុញ្ញាតនេះ មានសុពលភាពរយៈពេល ០១ (មួយឆ្នាំ) គិតពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រធានមន្ទីរ**

**ឃុត_សំខាន់**

***កន្លែងទទួល***
-ក្រសួងព័ត៌មាន
-អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍
-សាលារាជធានីភ្នំពេញ
(ដើម្បីជ្រាបជាព័ត៌មាន)
-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
-ឯកសារ-កាលប្បវត្តិ

អាស័យដ្ឋាន : លេខ២, មហាវិថីសហព័ន្ធរុស្ស៊ី, សង្កាត់មនោរម្យ, ខណ្ឌ៧មករា ។
Website: www.midphnompenh.com / E-mail: Midphnompenh@gmail.com

# ដំណើរនៃការអភិវឌ្ឍន៍វិស័យសន្តិសុខសង្គម











**បេឡាជាតិរបបសន្តិសុខសង្គម**

National Social Security Fund

អាសយដ្ឋានៈ អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី
សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទៈ (០២៣) ៨៨ ២៤ ៣៤ / ៩៩ ៨៤ ១៧
(០២៣) ៩៩ ៨៤ ១៨ / ៩៩ ៨៤ ១៩

Website: www.nssf.gov.kh

Email: info@nssf.gov.kh


**ទូរស័ព្ទទំនាក់ទំនងបន្ទាន់ ១២៨៦ បម្រើសេវា ២៤ម៉ោង/៧ថ្ងៃ**